ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០៥៦ សហវ.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល

### ឧបនាយករដ្ឋមន្ត្រី
### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦០ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ
- បានឃើញអនុក្រឹត្យលេខ ១៦៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២១ ស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៥៣ អនក្រ.បក ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ ស្តីពីការគ្រប់គ្រង ការប្រើប្រាស់និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបុគ្គល
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួងអនុវត្តប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល លើថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបណ្ណនៃក្រសួងមហាផ្ទៃ ដែលមានសមាសភាព ដូចខាងក្រោម៖

| | |
|---|---|
| - ឯកឧត្តម **គង់ ម៉ារី** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល | ប្រធាន |
| - ឯកឧត្តមឧត្តមសេនីយ៍ទោ **អ៊ុកចាយ បញ្ញារ៉ា** អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ | អនុប្រធាន |
| - ឯកឧត្តម **តាំង ខុនលី** នាយកមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" និងជាអគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការសេដ្ឋកិច្ច និងធុរកិច្ចឌីជីថល | អនុប្រធាន |
| - ឧត្តមសេនីយ៍ឯក **ឃៀង សុគន្ធា** ប្រធាននាយកដ្ឋានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ | សមាជិក |
| - លោកឧត្តមសេនីយ៍ត្រី **ឈុន វណ្ណា** ប្រធាននាយកដ្ឋានគ្រប់គ្រងប្រព័ន្ធព័ត៌មានវិទ្យា នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ | សមាជិក |
| - លោកឧត្តមសេនីយ៍ទោ **អ៊ីវ វាសនា** អនុប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |
| - លោកវរសេនីយ៍ឯក **លី វណ្ណី** នាយការិយាល័យ នាយកដ្ឋានព័ត៌មានវិទ្យា នៃអគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ | សមាជិក |
| - លោក **អៀច សេដ្ឋា** ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាននៃអគ្គលេខាធិការដ្ឋាន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| - លោក **ហាំង សុខសេរី** មន្ត្រីអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការសេដ្ឋកិច្ចនិងធុរកិច្ចឌីជីថល | សមាជិក |
| - លោក **ឌិត្យ ដារ៉ាយ៉ុង** អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់ នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" | សមាជិក |
| - លោក **ឃិន ភក់ឌឹង** អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់ នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" | សមាជិក |
| - លោក **ដារ៉ា ពេញចិត្ត** អ្នកអភិវឌ្ឍកម្មវិធីជាន់ខ្ពស់ | |

នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សមាជិក

- លោកស្រី **ផល ម៉ារីណា** អ្នកគ្រប់គ្រងកម្មវិធីនវានុវត្តន៍
  នៃមជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី "តេជោ" សមាជិកា។

**ប្រការ២.-**

ក្រុមការងារមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ពិនិត្យ សិក្សា និងវាយតម្លៃលក្ខណៈបច្ចេកទេសនិងគតិយុត្ត ក្នុងការគាំទ្រដល់ការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបណ្ណរបស់ក្រសួងមហាផ្ទៃតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីប្រើប្រាស់ក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល សំដៅគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធុរកិច្ច និងធនាគារ ប្រកបដោយភាពរហ័ស គុណភាព សុវត្ថិភាព ឯកជនភាព ទំនុកចិត្តនិងភាពជឿជាក់ ប្រសិទ្ធភាព និងសក្តិសិទ្ធិភាព
- ពិនិត្យ សិក្សា វាយតម្លៃ និងកំណត់តម្លៃសេវាក្នុងក្របខណ្ឌនៃការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបណ្ណរបស់ក្រសួងមហាផ្ទៃតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីប្រើប្រាស់ក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល សំដៅគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធុរកិច្ច និងធនាគារ ព្រមទាំងលើកសំណើសុំការពិនិត្យនិងការសម្រេចពីថ្នាក់ដឹកនាំលើតម្លៃសេវាដែលបានកំណត់ ជាគុណប្រយោជន៍ដល់ការប្រមូលថវិកាជាតិ
- ពិនិត្យនិងរៀបចំផែនការសកម្មភាពនិងហិរញ្ញវត្ថុសម្រាប់ការគាំទ្រដល់និរន្តរភាពការងារក្នុងការប្រើប្រាស់និងការផ្ទៀតផ្ទាត់ទិន្នន័យអត្តសញ្ញាណរបស់ក្រសួងមហាផ្ទៃតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា
- ពិនិត្យ សិក្សា វាយតម្លៃ និងលើកសំណើពាក់ព័ន្ធការសហការនិងការសម្របសម្រួល ក្នុងការគ្រប់គ្រងការប្រើប្រាស់ និងការការពារសុវត្ថិភាពទិន្នន័យអត្តសញ្ញាណបណ្ណរបស់ក្រសួងមហាផ្ទៃតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីប្រើប្រាស់ក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល
- ពិនិត្យនិងលើកសំណើដើម្បីពង្រឹងនិងពង្រីកវិសាលភាពព្រមទាំងកិច្ចប្រតិបត្តិការផ្ទៀងផ្ទាត់ទិន្នន័យអត្តសញ្ញាណបណ្ណរបស់ក្រសួងមហាផ្ទៃតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា ដើម្បីប្រើប្រាស់ក្នុងក្របខណ្ឌប្រព័ន្ធសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថល សំដៅគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យផ្សេងៗទៀតតាមការចាំបាច់
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីប្រធានក្រុមការងារ។

**ប្រការ៣.-**

សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីដែលប្រធានក្រុមការងារអវត្តមានឬមានករណីចាំបាច់ ប្រធានក្រុមការងារអាចផ្ទេរសិទ្ធិជូនអនុប្រធានណាមួយដឹកនាំកិច្ចប្រជុំ។ សមាជិកក្រុមការងារដែលមិនអាចចូលរួមកិច្ចប្រជុំបាន ត្រូវចាត់តំណាងក្នុងនាមក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនដើម្បីចូលរួមប្រជុំជំនួស។

**ប្រការ.៤.**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន និងប្រធានអង្គភាពដែលពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ៣ ៤ រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមេសា ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៤
- ឯកសារ កាលប្បវត្តិ